# កិច្ចប្រជុំផ្សព្វផ្សាយព្រឹត្តិការណ៍ និងគោលការណ៍សំខាន់ៗប្រចាំសប្តាហ៍ របស់ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

## ការអនុវត្តអភិបាលកិច្ច ក្រោមក្របខណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២

រៀបចំដោយៈ លេខាធិការដ្ឋាន គ.ជ.អ.ប.

# មាតិកា

១ សេចក្តីផ្តើម

២ គោលបំណង

៣ រូបមន្ត និងវិធីសាស្ត្រ

៤ លទ្ធផល

៥ អនុសាសន៍

# ១. សេចក្តីផ្តើម

## កម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០)

**គោលដៅ (Objective)៖**

រចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

**គោលបំណង (Goal)៖**

លើកកម្ពស់សេវា ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាបន្ន សមធម៌ និងយុត្តិធម៌ តាមរយៈធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច និងកែលម្អដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកលុបបំបាត់ភាពក្រីក្រ លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង




(២) សន្ទស្សន៍ការផ្តល់សេវា (៣) សន្ទស្សន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ

(១) សន្ទស្សន៍ផ្នែកអភិបាលកិច្ច

ការវាស់វែងលើការសម្រេចបានគោលដៅ គោលបំណង ចាំបាច់ត្រូវមានសន្ទស្សន៍ជាយុទ្ធសាស្ត្រចំនួន៣ បង្កើតឡើងតាមការអង្កេត

# ២. គោលបំណង

**សន្ទស្សន៍ការផ្តល់សេវា៖** សម្រាប់វាយតម្លៃលើគុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវា និងការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ




**សន្ទស្សន៍អភិបាលកិច្ច៖** សម្រាប់វាយតម្លៃលើកម្រិតនៃស្វ័យភាព តម្លាភាព គណនេយ្យភាព ក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការអង្កេតអភិបាលកិច្ចនេះ រៀបចំឡើងដោយប្រើពេលប្រមាណជាង ៧ខែ (សីហា ២០២៤ – មីនា ២០២៥)

# ៣. រូបមន្ត និងវិធីសាស្ត្រ

## រូបមន្តសម្រាប់បង្កើតសន្ទស្សន៍៖

សន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍ការផ្តល់សេវាត្រូវបង្កើតឡើងចេញពីសន្ទស្សន៍រងពាក់ព័ន្ធចំនួន៥ គឺ៖







សន្ទស្សន៍រងនីមួយៗត្រូវបង្កើតឡើងចេញពីសូចនាករពាក់ព័ន្ធ

សន្ទស្សន៍ និងសូចនាករត្រូវបានគណនាជាតម្លៃពី ០ ទៅ ១

# ៣. រូបមន្ត និងវិធីសាស្ត្រ (ត)

## វិធីសាស្ត្រចុះអង្កេត៖

### ការអង្កេតគ្របដណ្តប់ទូទាំងប្រទេស




- ✓ ២៥ រាជធានី ខេត្ត
- ✓ ៩៦ ក្រុង ស្រុក ខណ្ឌ
- ✓ ១៩២ ឃុំ សង្កាត់
- ✓ ៣៨៤ ភូមិ

### ការជ្រើសរើសសំណាកគំរូ ដោយចៃដន្យ (៣.៩០៨ នាក់)




ការអង្កេតអភិបាលកិច្ច ផ្ដោតលើ**ទស្សនៈរបស់ប្រជាពលរដ្ឋ** អាស្រ័យហេតុនេះ ក្នុងការគណនាតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រង**បានផ្ដល់ទម្ងន់ ឬមេគុណចំពោះចម្លើយរបស់ប្រជាពលរដ្ឋ**ច្រើនជាងចម្លើយរបស់ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺ៦៧% ទល់នឹង៣៣%។

# ៤. លទ្ធផល


ការបំពេញការងារ
ចំណាត់ថ្នាក់បង្គួរ (០,៦៧)
០១
ការឆ្លើយតប
០២
ចំណាត់ថ្នាក់ល្អ (០,៧៤)
លទ្ធផល
សន្ទស្សន៍ទ
ការចូលរួមរបស់ប្រជាពលរដ្ឋ
០៥
ចំណាត់ថ្នាក់មធ្យម (០,៥៨)
តម្លាភាព
០៣
ចំណាត់ថ្នាក់បង្គួរ (០,៦២)
គណនេយ្យភាព
០៤
ចំណាត់ថ្នាក់មធ្យម (០,៥៤)
ការផ្តល់សេវា
ចំណាត់ថ្នាក់បង្គួរ (០,៦៩)
សន្ទស្សន៍ជាយុទ្ធសាស្ត្រ
អភិបាលកិច្ច
ចំណាត់ថ្នាក់បង្គួរ (០,៦៤)
លទ្ធផលអង្កេតអភិបាលកិច្ច


ការបំពេញការងារ
0.៦៧
75%
ការឆ្លើយតប
0.៧៤
25%
សន្ទស្សន៍សេវា
0.៦៩
55%
តម្លាភាព
0.៦២
15%
គណនេយ្យភាព
0.៥៤
15%
ការចូលរួម
0.៥៨
15%
សន្ទស្សន៍អភិបាលកិច្ច
0.៦៤

# ៤. លទ្ធផល (ត)

តម្លៃសន្ទស្សន៍រងនីមួយៗបង្កើតឡើងចេញពីតម្លៃសូចនាករពាក់ព័ន្ធ

| សន្ទស្សន៍រងការបំពេញការងារ | ០,៦៧ |
|---|---|
| ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះគុណភាពសេវាសាធារណៈសំខាន់ៗ | ០,៦១ |
| ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាល | ០,៦៩ |
| ភាពពេញចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះសមត្ថភាព និងធនធានដែលខ្លួនមានសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ | ០,៦៩ |

| សន្ទស្សន៍រងការឆ្លើយតប | ០,៧៤ |
|---|---|
| អាទិភាពរបស់ប្រជាពលរដ្ឋត្រូវគ្នានឹងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៨៣ |
| ប្រជាពលរដ្ឋយល់ថារដ្ឋបាលថ្នាក់ក្រោមជាតិយល់ដឹងពីបញ្ហារបស់ប្រជាពលរដ្ឋ និងព្យាយាមដោះស្រាយបញ្ហាទាំងនេះ | ០,៧២ |
| រដ្ឋបាលថ្នាក់ក្រោមជាតិ យល់ថាតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋមានសារសំខាន់បំផុតក្នុងដំណើរការការកសាងផែនការ និងគម្រោងថវិកា | ០,៧២ |

| សន្ទស្សន៍រងតម្លាភាព | ០,៦២ |
|---|---|
| ប្រជាពលរដ្ឋយល់ដឹងអំពីតួនាទី ភារកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៤០ |
| ប្រជាពលរដ្ឋដឹងអំពីសិទ្ធិទទួលបានព័ត៌មានពីរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៧៦ |
| ប្រជាពលរដ្ឋជឿថាតម្លៃសេវា និងការបង់តម្លៃសេវាមានតម្លាភាព | ០,៥៧ |
| មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមានឥរិយាបថវិជ្ជមានចំពោះតម្លាភាព | ០,៧៦ |
| ភាពសកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ | ០,៦៩ |

# ៤. លទ្ធផល (ត)

| សន្ទស្សន៍វងគណនេយ្យភាព | ០,៥៤ |
|---|---|
| ប្រជាពលរដ្ឋជឿថាអាចដាក់បណ្តឹងតវ៉ាក្នុងករណីមិនពេញចិត្តចំពោះការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៥០ |
| ប្រជាពលរដ្ឋជឿថាសំឡេងឆ្នោតរបស់ខ្លួនមានឥទ្ធិពលលើការបំពេញការងាររដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៤៧ |
| ប្រជាពលរដ្ឋជឿថាបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលទណ្ឌកម្ម ប្រសិនបើបំពេញការងារមិនបានល្អ ឬរំលោភច្បាប់ | ០,៦៤ |
| បុគ្គលិកថ្នាក់ក្រោមជាតិរាយការណ៍ថា មានយន្តការដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព | ០,៦០ |
| ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិយល់ថា មានតម្រូវការក្នុងការទាក់ទាញសំឡេងឆ្នោតនាពេលអនាគត | ០,៤២ |
| ក្រុមប្រឹក្សា និងមន្ត្រីដឹងថានឹងទទួលទណ្ឌកម្ម ប្រសិនបើបំពេញការងារមិនបានល្អ ឬរំលោភច្បាប់ | ០,៦៤ |

| សន្ទស្សន៍វងការចូលរួមរបស់ប្រជាពលរដ្ឋ | ០,៥៨ |
|---|---|
| ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិបាលកិច្ច និងអភិវឌ្ឍន៍មូលដ្ឋាន | ០,៦៦ |
| ប្រជាពលរដ្ឋពេញចិត្តចំពោះការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៦៨ |
| ប្រជាពលរដ្ឋចូលក្នុងអង្គការសហគមន៍មូលដ្ឋាន | ០,២៣ |
| រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពសកម្មក្នុងការស្វែងរកមតិយោបល់របស់ប្រជាពលរដ្ឋ | ០,៦៧ |
| រដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់វិធីផលសម្រាប់ការប្រាស័យទាក់ទងជាមួយប្រជាពលរដ្ឋ | ០,៥៣ |
| រដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការជាមួយអង្គការសហគមន៍មូលដ្ឋាន | ០,៧១ |

# ៥. អនុសាសន៍

សន្ទស្សន៍ទាំងនេះ គឺជាសន្ទស្សន៍ដើមគ្រាឆ្នាំ២០២៤ វាពុំទាន់អាចឆ្លុះបញ្ចាំងអំពីកម្រិតនៃការសម្រេចគោលបំណង និងគោលដៅនៃកជទី២នាពេលនេះឡើយៗ ក៏ប៉ុន្តែ សន្ទស្សន៍នេះ មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ជាមូលដ្ឋានក្នុងការវាស់វែងការប្រែប្រួលតម្លៃសន្ទស្សន៍ទាំងនេះ នៅពេលធ្វើអង្កេតនាពេលពាក់កណ្ដាលឆ្នាំបន្ទាប់ ឬនៅពេលបញ្ចប់ កជទី២ៗ ក្នុងន័យនេះ ដើម្បីធានាឱ្យមានការប្រែប្រួលជាវិជ្ជមាននូវសន្ទស្សន៍ទាំងនេះ ត្រូវផ្ដោតលើកិច្ចការចាំបាច់ដូចខាងក្រោម៖

## ការបំពេញការងារ

បន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលជាអាទិភាពខ្ពស់របស់ប្រជាពលរដ្ឋ និងផ្ដោតលើការផ្ដល់សេវាការគាំទ្រដល់ក្រុមជនងាយរងគ្រោះ

## ការឆ្លើយតប

ផ្ដល់អាទិភាពចំពោះខស្សែនៈ យល់ឃើញរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការ និងត្រូវធានាថាមតិយោបល់ តម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានស្ដាប់ និងយកមកពិចារណាក្នុងដំណើរការរៀបចំផែនការ

## តម្លាភាព

បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីតួនាទី និងការផ្ដល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវលើកកម្ពស់តម្លាភាពអំពីកម្រៃសេវា បង្កើនការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការផ្សព្វផ្សាយព័ត៌មានជូនសាធារណជន

## គណនេយ្យភាព

កែលម្អយន្តការទទួល និងដោះស្រាយបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋ ដោយផ្ដោតលើថ្នាក់ដឹកនាំភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ពីព្រោះប្រជាពលរដ្ឋភាគច្រើននាំយកទុក្ខព្រួយរបស់ខ្លួនទៅកាន់ភូមិ និងឃុំ សង្កាត់មុនគេ

## ការចូលរួមរបស់ប្រជាពលរដ្ឋ

ប្រើប្រាស់វិធីសាស្ត្រនានាឱ្យបានទូលំទូលាយ និងទំនើបជាងមុនសម្រាប់ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ បង្កើតភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន លើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមតាមរយៈសហគមន៍មូលដ្ឋាន

គេហទំព័រ គ.ជ.អ.ប.
www.ncdd.gov.kh

ឯកសារបទបង្ហាញ

របាយការណ៍
ការអង្កេតអភិបាលកិច្ច

# សូមអរគុណ